# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1251

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ការពង្រឹងការគ្រប់គ្រងការបំពុលខ្យល់ និងបរិយាកាសនៅកម្ពុជា

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 31/12/20

កាលបរិច្ឆេទបញ្ចប់គម្រោង 31/12/22

៣. ចំណាយគម្រោងសរុប $216,679

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងបរិស្ថាន

RESPONSIBLE UNIT Department of Air Quality and Noise Management, Directorate General of Environmental Protection, Ministry of Environment

អង្គភាពទទួលខុសត្រូវ នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់និងសំឡេងអគ្គនាយកដ្ឋានគាំពារ បរិស្ថាន

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៥- ការពង្រឹងប្រព័ន្ធធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះនឹងគាំទ្រដល់ផែនការខ្យល់ស្អាតដោយប្រើប្រាស់ឧបករណ៍ដើម្បីត្រួតពិនិត្យប្រភពបំពុលនិងគុណភាពខ្យល់នៅក្នុងតំបន់និង ផ្តល់ការយល់ដឹងកាន់តែច្បាស់អំពីការបំភាយឧស្ម័នចេញពីប្រភពបំពុលបរិយាកាស។ វាក៏នឹងគាំទ្រផងដែរ ក្នុងការបង្កើតក្រុមការងារអន្តរក្រសួងក្នុងការអភិវឌ្ឍគោលនយោបាយ និងបទប្បញ្ញត្តិជាតិ។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

កំពត, ស្វាយរៀង, ឧត្តរមានជ័យ, សៀមរាប, កំពង់ស្ពឺ, កំពង់ចាម, បន្ទាយមានជ័យ, បាត់ដំបង, រាជធានីភ្នំពេញ, ព្រះសីហនុ, កណ្ដាល,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

ដើម្បីលើកកម្ពស់ការត្រួតពិនិត្យ និងការគ្រប់គ្រងការបំពុលបរិយាកាស និងអាកាសធាតុដោយបង្កើន សមត្ថភាពរបស់មន្ត្រីនាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់និងសំឡេង និងមន្ទីរខេត្តនៃក្រសួងបរិស្ថាន និងធ្វើឲ្យ ប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការអន្តរក្រសួងស្តីពីគោលនយោបាយទាក់ទងនឹងសកម្មភាព ។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

១. ការធ្វើវិសោធនកម្មអនុក្រឹត្យ ស្តីពីការគ្រប់គ្រងការបំពុលខ្យល់ និងរំខានដោយសំឡេង និងការគ្រប់គ្រងរំញ័រ ក្រោមការសម្របសម្រួលរបស់នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់និងសំឡេង

២. បង្កើតទម្រង់ទិន្នន័យស្តីពីការត្រួតពិនិត្យ និងបណ្តុះបណ្តាលគុណភាពបរិយាកាសដល់មន្ត្រីនាយកដ្ឋាន គ្រប់គ្រងគុណភាពខ្យល់និងសំឡេង

៣. ការសាកល្បងសារធាតុបំពុលខ្យល់មានអាយុខ្លីក្នុងបរិយាកាស (SLCPs) ពិសេសលើកាបូនខ្មៅ និងការ បំពុលខ្យល់ពីប្រភពអចល័ត និងការពង្រឹងសមត្ថភាពលើផែនការគ្រប់គ្រងគុណភាពខ្យល់ និងការកាត់បន្ថយសារធាតុ បំពុលខ្យល់មានអាយុខ្លីក្នុងបរិយាកាស (SLCPs) នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

កម្ពុជាមានបញ្ហាប្រឈម និងបញ្ហាដែលត្រូវដោះស្រាយរួមមានៈ
- ទំនោរនៃការបង្កើនកម្រិតនៃការបំពុលខ្យល់នៅក្នុងបរិយាកាស
- អនុក្រឹត្យបច្ចុប្បន្នមិនទាន់ឆ្លើយតបទៅនឹងកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងស្ថានភាពបច្ចុប្បន្ននៃការបំពុល បរិស្ថាន
- មិនទាន់មានការបំពាក់គ្រប់គ្រាន់នូវឧបករណ៍ត្រួតពិនិត្យ SLCP និងការបំពុលបរិយាកាសពីប្រតិបត្តិករផ្សេងៗ របស់រោងចក្រលើវិធានការកាត់បន្ថយដែលមានសក្តានុពល
- មិនមានទម្រង់ទិន្នន័យសម្រាប់ការត្រួតពិនិត្យគុណភាពខ្យល់និងការបំភាយឧស្ម័នបំពុលបរិស្ថានពីឧស្សាហកម្ម និងសមត្ថភាពប្រើប្រាស់ប្រព័ន្ធនៅមានកម្រិត។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

១. គម្រោងនេះនឹងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដែលមានស្រាប់របស់នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់និងសំឡេង។
២. គាំទ្រក្នុងការបង្កើតក្រុមការងារអន្តរក្រសួងក្នុងការអភិវឌ្ឍគោលនយោបាយនិងបទប្បញ្ញត្តិជាតិ។
៣. គាំទ្រដល់ការគ្រប់គ្រងគុណភាពខ្យល់សាធារណៈនិងការការពារសុខភាពសាធារណៈ។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | គ្មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | មិនទានចាប់ផ្តើម |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

សំឡេងចេញពីសហគមន៍ដែលរងផលប៉ះពាល់ជាពិសេសស្ត្រី និងក្រុមងាយរងគ្រោះនឹងត្រូវបានគេលើកឡើង ក្នុងអំឡុងពេលចុះបេសកកម្មអង្កេតតាមដាននិងត្រូវបានគេចាត់ទុកថាជាធាតុចូលដ៏សំខាន់សម្រាប់គោលនយោបាយ និងការអភិវឌ្ឍបទបញ្ញត្តិ។ គម្រោងនេះនឹងផ្តល់នូវផលវិជ្ជមានដល់សុខភាពប្រជាជននៅទីតាំងគម្រោង (ទីតាំង ត្រួតពិនិត្យគុណភាពខ្យល់) ហើយក្រុមអ្នកក្រ និងក្រុមងាយរងគ្រោះនឹងទទួលបានអត្ថប្រយោជន៍សុខភាពពីវិធាន ការណ៍គ្រប់គ្រងការបំពុលបរិស្ថានដែលបានអនុវត្តដោយរដ្ឋាភិបាល។ ហេតុនេះ គម្រោងនេះនឹងចូលរួមចំណែក កាត់បន្ថយភាពក្រីក្រ។

១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការកាត់បន្ថយ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|
| **១៤. ការកាត់បន្ថយការបញ្ចេញឧស្ម័ន** | 65 | **ទាក់ទងមធ្យម** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការបង្ការ**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះមិនប៉ះពាល់ដល់តួនាទីបុរសនិងស្ត្រីទេ ប៉ុន្តែស្ត្រីត្រូវបានលើកទឹកចិត្តឲ្យមានការចូលរួមយ៉ាងសកម្មជាមួយនឹងការអនុវត្តគម្រោងនេះ។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**គម្រោងនេះបានបង្កើតក្រុមការងារគម្រោងដោយចាត់តាំងមន្ត្រីពីនាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ និងសំឡេង ទោះយ៉ាងណាក៏ដោយ គម្រោងនេះត្រូវការជ្រើសរើសអ្នកជំនាញជាតិឬអន្តរជាតិបន្ថែម។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**គម្រោងបាននឹងកំពុងដំណើរការពីដើមឆ្នាំ២០២១ និងបញ្ចប់ឆ្នាំ២០២២**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

5

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**គម្រោងនេះបានទទួលហិរញ្ញប្បទានពី សម្ព័ន្ធប្រែប្រួលអាកាសធាតុកម្ពុជា** (CCCA)។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 31.0 | 0.0 | 29.8 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| បៀវត្សរ៍ | 26.6 | 0.0 | 26.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 2.4 | 0.0 | 1.2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 2.0 | 0.0 | 2.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| **ចំណាយមូលធន** | 93.4 | 0.0 | 62.5 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការសាងសង់ | 1.8 | 0.0 | 1.8 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 9.3 | 0.0 | 9.3 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទិញសម្ភារៈ | 56.0 | 0.0 | 25.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 18.8 | 0.0 | 18.9 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 7.5 | 0.0 | 7.5 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| **ចំណាយសរុប** | 124.4 | 0.0 | 92.3 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |

| ប្រភពហិរញ្ញប្បទាន | 2021 | | 2022 | 2023 | 2024 | 2025 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2023-2025 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 124.4 | 0.0 | 92.3 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Cambodia Climate Change Alliance | 124.4 | 0.0 | 92.3 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 124.4 | 0.0 | 92.3 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: